# COVID-19: បទប្បញ្ញត្តិថ្មី សម្រាប់គ្រួសារ និងអ្នកទំនាក់ទំនងជិតស្និទ្ធនៅក្នុងរដ្ឋ NSW

ប្រសិនបើអ្នកជាអ្នកទំនាក់ទំនងគ្រួសារ ឬអ្នកទំនាក់ទំនងជិតស្និទ្ធ ហើយមិនមានរោគសញ្ញា COVID-19 ណាមួយ អ្នកមិនចាំបាច់ដាក់ខ្លួនឱ្យនៅដាច់ពីគេទេ ប៉ុន្តែអ្នកត្រូវតែធ្វើតាមដំបូន្មានរបស់ NSW Health៖

- កុំទៅកន្លែងដែលមានហានិភ័យខ្ពស់ ដូចជាមន្ទីរពេទ្យ និងកន្លែងថែទាំមនុស្សចាស់
- ធ្វើការ ឬសិក្សាពីផ្ទះ ពេលណាដែលអាចធ្វើទៅបាន។ អ្នកចាំបាច់ត្រូវការការយល់ព្រមពីនិយោជក ឬកន្លែងអប់រំរបស់អ្នក ប្រសិនបើអ្នកត្រូវការទៅធ្វើការ ឬសាលារៀន
- ពាក់ម៉ាស់នៅក្នុងអគារ ប្រសិនបើអ្នកមានអាយុ១២+ ឆ្នាំ។ អ្នកមិនចាំបាច់ពាក់ម៉ាស់នៅក្នុងផ្ទះរបស់អ្នកទេ។
- ជៀសវាងការជួបជុំមនុស្សច្រើនកកកុញ ឬមានមនុស្សច្រើននៅក្នុងអគារ ជាមួយមនុស្សដែលអ្នកមិនរស់នៅជាមួយ។ ប្រសិនបើអ្នកត្រូវការចូលរួម សូមធ្វើតេស្តអង់ទីហ្សែនរហ័ស មុនពេលអ្នកទៅ

អនុវត្តតាមបទប្បញ្ញត្តិសម្រាប់រយៈពេល៧ថ្ងៃ ចាប់ពីពេលចុងក្រោយដែលបុគ្គលម្នាក់ក្នុងគ្រួសាររបស់អ្នកបានធ្វើតេស្តវិជ្ជមាន COVID-19។

ប្រសិនបើអ្នកមាន ឬកើតមានរោគសញ្ញា អ្នកត្រូវតែដាក់ខ្លួនឱ្យនៅដាច់ពីគេ ហើយធ្វើតេស្តរកមើល COVID-19។ សូមធ្វើតាមដំបូន្មានរបស់ NSW Health ប្រសិនបើលទ្ធផលតេស្តរបស់អ្នកវិជ្ជមាន។

ប្រសិនបើលទ្ធផលតេស្តរបស់អ្នកអវិជ្ជមាន សូមស្នាក់នៅផ្ទះ រហូតដល់អ្នកមិនមានរោគសញ្ញាណាមួយ។

**សូមចូលទៅកាន់គេហទំព័រ www.nsw.gov.au/covid-19/management/household-contacts សម្រាប់ព័ត៌មានបន្ថែម។**



© NSW Health April 2022.